# សូមមានសុវត្ថិភាព ។ សូមកុំឱ្យមានការរំខាន !

អ្នកអាចរងរបួស ឬស្លាប់ ប្រសិនបើអ្នកធ្វើឱ្យទូរស័ព្ទដៃរបស់អ្នករំខានអ្នក ខណៈពេលបើកបរ ។

ស្ថិតិថ្មីៗនេះបង្ហាញថាឱកាសរបស់អ្នកក្នុងការទទួលរងគ្រោះថ្នាក់កើនដល់ 400% ខណៈពេលប្រើប្រាស់ទូរស័ព្ទដៃរបស់អ្នក ។



## California Public Utilities Commission

### Telecommunications Education and Assistance in Multiple-Languages (TEAM) Program

www.cpuc.ca.gov/team-and-changes

cabteamandchanges@cpuc.ca.gov

If you are not able to resolve your dispute with your service provider, call the Consumer Affairs Branch (800) 649-7570

# សូមមានសុវត្ថិភាព

## សូមកុំប្រើប្រាស់ទូរស័ព្ទដៃរបស់អ្នកខណៈពេលបើកបរ

CALIFORNIA PUBLIC UTILITIES COMMISSION





## វាមានគ្រោះថ្នាក់ ។

### វាមានគ្រោះថ្នាក់ក្នុងការ

### ប្រើប្រាស់ទូរស័ព្ទដៃខណៈពេលបើកបរ

- ការផ្ញើសារខណៈពេលបើកបរ អាចពន្យារការមាន-ប្រតិកម្មរបស់អ្នកច្រើន ដូចមានចំណុះជាតិស្រវឹងក្នុងឈាម (BAC) ចំនួន .08 ។ នេះគឺវាដូចគ្នាជាមួយនឹងអ្នកបើក-បរស្រវឹងដែរ ។
- ការផ្ញើសារ ធ្វើឱ្យភ្នែករបស់អ្នកចេញឆ្ងាយពីផ្លូវជាមធ្យមប្រាំវិនាទី។ នេះគឺយូរវែងគ្រប់គ្រាន់ ក្នុងការធ្វើដំណើរតាមបណ្ដោយ-តារាង

បាល់ទាត់ក្នុងល្បឿន 55 mph ។ គ្រោះថ្នាក់ភាគច្រើនកើតឡើង

ជាមួយពេលវេលាប្រតិកម្មតិចជា 3 វិនាទី ។

# សូមមានសុវត្ថិភាព ! សូមកុំប្រើប្រាស់ទូរស័ព្ទដៃរបស់អ្នក ខណៈពេលបើកបរ

## វាល្មើសនឹងច្បាប់ ។

### ច្បាប់រដ្ឋកាលីហ្វ័រញ៉ាចែងថា៖

- ការផ្ញើសារ ខណៈពេលបើកបរ គឺល្មើសនឹងច្បាប់ ។
- ការនិយាយទូរស័ព្ទដៃរបស់អ្នក ខណៈពេលបើកបរ គឺល្មើសនឹងច្បាប់សម្រាប់អ្នកមានអាយុក្រោម 18 ឆ្នាំ ។ ជនពេញវ័យអាចនិយាយទូរស័ព្ទដៃរបស់ពួកគេ ប៉ុន្តែមិនត្រូវបានអនុញ្ញាតឱ្យកាន់ទូរស័ព្ទដៃ ខណៈពេលបើកបរនោះទេ ។ អ្នកគ្រប់គ្នាអាចប្រើប្រាស់ទូរស័ព្ទដៃ ដើម្បីធ្វើការហៅទូរស័ព្ទបន្ទាន់ ។ សូម្បីដូច្នេះ

  វាគឺឆ្លាតវៃក្នុងការទៅកាន់កន្លែងណាមួយ ដែលមានសុវត្ថិភាពជាដំបូងសិន ។
- សម្រាប់ការផ្ញើសារ ឬការខកខានប្រើប្រាស់ឧបករណ៍មិនរំខានដល់ដៃដោយទូរស័ព្ទដៃរបស់អ្នក ការពិន័យអាចចាប់មានពីប្រមាណ $160 ហើយអាចកើនឡើងជាមួយនឹងសំបុត្រពិន័យបន្ថែម។

## ស្ថិតិ

ច្បាប់នេះ និងកម្មវិធីយល់ដឹងបានចូលជាធរមានក្នុងឆ្នាំ 2008 ។ តាំងពីពេលនោះមក គ្រោះថ្នាក់បានថយចុះ ។ ទោះជាយ៉ាងនេះក្ដី មនុស្សច្រើនកៃនៅរងរបួស ឬស្លាប់ ដោយសារពួកគេបន្តប្រើប្រាស់ទូរស័ព្ទដៃរបស់ពួកគេ ខណៈពេលបើកបរ ។

រវាងឆ្នាំ 2008 និង 2010 អ្នកបើកបរក្នុងរដ្ឋកាលីហ្វ័រញ៉ាចំនួន 53 នាក់បានស្លាប់ ខណៈពេលកាន់ទូរស័ព្ទដៃរបស់ពួកគេ ។ ទូរស័ព្ទដៃហាក់ដូចជាកត្តាមួយក្នុងការស្លាប់ ក្នុងចរាចរណ៍ដទៃទៀតផងដែរ ដោយសារតែ-មូលហេតុចំបងនៃការបើកបរដោយការរំខាន គឺការប្រើប្រាស់ទូរស័ព្ទដៃ ។ ក្នុងការសិក្សាថ្មីៗនេះរបស់និស្សិតមហាវិទ្យាល័យកាលីហ្វ័រញ៉ាចំនួន 5.000 នាក់ 18% បាននិយាយថា ពួកគេ

បានស្ថិតក្នុងគ្រោះថ្នាក់បើកបរដោយការរំខាន ។ ក្នុងចំណោមនោះ 22 % គឺដោយសារការផ្ញើសារ និង 14 % ដោយសារការនិយាយទូរស័ព្ទដៃ ។







## ការមើលមិនឃើញដោយមិនយកចិត្តទុកដាក់

ការសិក្សាបង្ហាញថា ការនិយាយតាមទូរស័ព្ទដៃគឺគ្រោះថ្នាក់។ អ្នកដែលនិយាយ-តាមទូរស័ព្ទ មានបទពិសោធមើលមិនឃើញដោយមិនយកចិត្តទុកដាក់ ។

ពោលគឺពេលដែលខួរក្បាលរបស់អ្នក មិនអាចឃើញនូវអ្វីត្រូវនៅចំពោះមុខអ្នក ដោយសារអ្នករវល់ពេកជាមួយការហៅទូរស័ព្ទរបស់អ្នក ។

## សូមកុំស្ថិតក្នុងស្ថិតិនោះ ។ សូមកុំធ្វើអ្នកដទៃចងចាំ ។ សូមបិទទូរស័ព្ទរបស់អ្នក ខណៈពេលបើកបរ ។

សម្រាប់ព័ត៌មានបន្ថែម សូចចូលមើលគេហទំព័រការល្បាតផ្លូវរដ្ឋកាលីហ្វ័រញ៉ា (California Highway Patrol) និងការិ-យាល័យសុវត្ថិភាពចរាចរណ៍កាលីហ្វ័រញ៉ា (California Office of Traffic Safety)។

សម្រាប់រឿងពិតទាក់ទងនឹងទូរស័ព្ទដៃ និងការបើកបរសូមមើល http://www.distraction.gov/content/faces/index.html ។